# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រុមហ៊ុនវ៉ាយអិនថិច ឯ.ក

## កិច្ចព្រមព្រៀង

## ស្តីពី

ព្យួរកិច្ចសន្យាការងារ

ក្រុមហ៊ុន វ៉ាយអិនថិច ឯ.ក ដែលមានអាស័យដ្ឋានភូមិផ្សារដែកលើ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល សូមធ្វើកិច្ចព្រមព្រៀងជាមួយប្រតិភូពេញសិទ្ធិប្រចាំក្រុមហ៊ុន និងតំណាងសហជីពប្រចាំក្រុមហ៊ុនដូចតទៅ៖

១.ក្រុមហ៊ុនស្នើសុំធ្វើការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត តាមបញ្ជីឈ្មោះដែលបានភ្ជាប់ជូនចំនួន ១១២ នាក់ (ស្រី ៩៤ នាក់) ក្នុងចំណោមកម្មករនិយោជិតសរុប ៦៣២នាក់ (ស្រី៤៧០នាក់)។

២.ព្យួរកិច្ចសន្យាការងាររយៈពេល ៣១ថ្ងៃ ដោយគិតចាប់ពីថ្ងៃ០១ ខែតុលា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២។

៣.ក្រុមហ៊ុនយល់ព្រមផ្តល់ប្រាក់ឧបត្ថមសម្រាប់ការព្យួរកិច្ចសន្យាការងារចំនួន ៤០ ដុល្លាអាមេរិច យោងតាមមាត្រា ៧១ និង៧២ ស្តីពីច្បាប់ការងារ។

៤.ក្រុមហ៊ុន និងធ្វើការបើកប្រាក់ឧបត្ថមជូនបងប្អូនកម្មករ និយោជិតរៀងរាល់ថ្ងៃទី១០នៃខែបន្ទាប់នៅក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារ។

៥.យើងខ្ញុំជាប្រតិភូពេញសិទ្ធិ/តំណាងសហជីពមូលដ្ឋាន បានចូលរួមពិភាក្សា និងអាននូវអត្ថន័យកិច្ចព្រមព្រៀងនេះ ព្រមទាំងយល់ព្រមលើលក្ខខណ្ឌដែលបានរៀបរាប់ខាងលើ។

ដើម្បីជាសម្គាល់យើងខ្ញុំជាប្រតិភូពេញសិទ្ធិប្រចាំក្រុមហ៊ុន និង តំណាងសហជីពមូលដ្ឋាន សូមធ្វើការផ្តិត មេដៃស្តាំជាភស្តុតាង។

ថ្ងៃព្រហស្បត៍ ៥រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កណ្តាល ថ្ងៃទី...១៥...ខែ...កញ្ញា... ឆ្នាំ២០២២

ហត្ថលេខានិងត្រាក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន វ៉ាយអិនថិច ឯ.ក YNTEX CO., LTD KINGDOM OF CAMBODIA

រស់ សុភា

ថ្ងៃព្រហស្បតិ៍ ៥ រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កណ្ដាល ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០២២

ស្នាមមេដៃប្រតិភូពេញសិទ្ធ និងតំណាងសហជីព